មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការផ្តល់វិធានការការពារចំពោះសាក្សីផ្តល់សក្ខីកម្ម អំពីគុកក្រាំងតាចាន់

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥

***លីម ជ័យទត្ត***
***អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម***
***មជ្ឈមណ្ឌលឯកសារកម្ពុជា***

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមបានសម្រេចផ្តល់វិធានការការពារចំពោះសាក្សីមួយរូបឈ្មោះ ស្រី ថន ដែលត្រូវបានកោះហៅឲ្យចូលមកផ្តល់សក្ខីកម្មទាក់ទងនឹងមន្ទីរសន្តិសុខត្រាំងតាចាន់ ជាទីដែលមនុស្សច្រើនជាង១៧,០០០នាក់ត្រូវបានសម្លាប់ ។[១] ដើម្បីផ្តល់ការការពារចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់មិនឲ្យមានការផ្សព្វផ្សាយអំពីអាស័យដ្ឋាន និងរូបភាពរបស់សាក្សីដល់សាធារណជនឡើយ ប្រព័ន្ធផ្សព្វផ្សាយនានាក៏ពុំត្រូវបានអនុញ្ញាតឲ្យផ្សព្វផ្សាយអំពីរូបថត ឬរូបភាពរបស់សាក្សីរូបនេះដែរ ទោះបីជារូបថតនោះដែលត្រូវបានថតនៅមុនពេលសាក្សីរូបនេះចូលមកផ្តល់សក្ខីកម្មយ៉ាងណាក៏ដោយ ។ វិធានការនេះត្រូវបានដាក់ឲ្យអនុវត្ត បន្ទាប់ពីមានការស្នើសុំពីសាក្សី ដោយសារមានការព្រួយបារម្ភពីបញ្ហាសុវត្ថិភាព ។ យោងតាមសក្ខីកម្មរបស់សាក្សី ស្រី ថន ដែលរៀបរាប់នៅក្នុងអំឡុងពេលសវនាការថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ សាក្សីរូបនេះ គឺជាអតីតយោធាខ្មែរក្រហមនៅភូមិភាគនិរតី ហើយក៏ជាអ្នកដែលបានដឹងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងមន្ទីរសុខក្រាំងតាចាន់ ។

ចាប់តាំងពីការចាប់ផ្តើមនីតិវិធីសវនាការលើសំណុំរឿង០០២ នៅក្នុងឆ្នាំ២០១១ នេះជាលើកទី១ហើយ ដែលសាក្សីចូលមកផ្តល់សក្ខីកម្មបានស្នើសុំវិធានការការពារដោយពុំចង់ឲ្យមានការបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួនជាសាធារណៈ ។ ជាការពិត ការមិនបង្ហាញអត្តសញ្ញាណរបស់សាក្សីជាសាធារណៈ គឺជាមធ្យោបាយមួយ ដើម្បីធានាសន្តិសុខផ្លូវចិត្តរបស់សាក្សីដែលព្រួយបារម្ភថាអាចនឹងមានបញ្ហាកើតឡើងដោយសារការផ្តល់សក្ខីកម្មរបស់ខ្លួន ។ម្យ៉ាងវិញទៀត ការសម្រេចផ្តល់វិធានការការពារដល់សាក្សីពីសំណាក់អង្គជំនុំជម្រះ គឺដើម្បីធានាថាសាក្សីមានសន្តិសុខ សុវត្ថិភាព និងមិនមានអារម្មណ៍ភ័យខ្លាចអំពី

---

[១] ដីកាដំណោះស្រាយ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០, ឯកសារលេខ D៤២៧, កថាខណ្ឌទី៥១៤ ។

ការផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ និងកន្លែងផ្សេងៗទៀតនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាអង្គជំនុំជម្រះបានសម្រេចឲ្យមានការបំប្លែងរូបភាពរបស់សាក្សីតាមរយៈប្រព័ន្ធបច្ចេកវិជ្ជាទំនើប (ធ្វើឲ្យរូបមើលពុំច្បាស់) និងមិនអនុញ្ញាតឲ្យបង្ហាញអំពីអាស័យដ្ឋានរបស់សាក្សីនៅអំឡុងនៃការផ្តល់សក្ខីកម្មក៏ដោយ ប៉ុន្តែអង្គជំនុំជម្រះពុំបានហាមឃាត់មិនឲ្យបង្ហាញឈ្មោះរបស់សាក្សីនេះទេ ។

វិធានការការពារដែលត្រូវដាក់ឲ្យអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំមែនមានត្រឹមតែការមិនបង្ហាញរូបភាព រូបថត ឬមិនបង្ហាញអំពីអាស័យដ្ឋានទេ ប៉ុន្តែមានវិធានការជាច្រើនផ្សេងទៀតដែលអង្គជំនុំជម្រះអាចសម្រេចដាក់ឲ្យអនុវត្តន៍ ដើម្បីធ្វើយ៉ាងណាអាចលាក់បាំងអត្តសញ្ញាណរបស់បុគ្គលដែលទទួលបានការការពារ ដោយពិនិត្យមើលលើកាលៈទេសៈ និងករណីជាក់ស្តែង ។ វិធានការទាំងនោះមានដូចជា ៖

- ការប្រើប្រាស់អាស័យដ្ឋានផ្សេងដើម្បីធ្វើការទំនាក់ទំនង
- ការប្រើរហស្សនាមនៅពេលនិយាយទៅរកបុគ្គលដែលត្រូវបានការពារ
- ការលាក់អត្តសញ្ញាណដោយមិនចាំបាច់សរសេរចូលក្នុងសំណុំរឿង
- នៅពេលជនត្រូវចោទ ឬជនសង្ស័យស្នើឲ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឲ្យមានការចូលរួមពីចម្ងាយ ឬបំប្លែងសំឡេងដើម ឬបិទភិនភាគរបស់ជននោះ ។
- អង្គជំនុំជម្រះអាចរៀបចំសវនាការជាសម្ងាត់ ឬអនុញ្ញាតឲ្យបង្ហាញភ័ស្តុតាងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬប្រើប្រាស់មធ្យោបាយផ្សេងៗទៀត ។
- បង្គាប់ឲ្យធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរដោយរក្សាទុកតាមរបៀបបិទស្លាកបោះត្រា
- ការហាមឃាត់សាធារណជនមិនឲ្យចូលពិនិត្យមើលឯកសារពិសេសណាមួយក្នុងសំណុំរឿងដែលបង្ហាញពីអត្តសញ្ញាណនៃបុគ្គលដែលទទួលបានការការពារ ។
- ចេញវិធានការដើម្បីការពារជារូបវន្តដល់បុគ្គលដែលត្រូវការពារ ជាពិសេសផ្តល់ជាកន្លែងស្នាក់នៅដែលមានសុវត្ថិភាព នៅក្នុង ឬក្រៅប្រទេសកម្ពុជា ។

(សូមមើលលម្អិតនៅក្នុងវិធាន២៩ នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំស្តីពីការអនុវត្តវិធានការការពាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលធ្វើវិសោធនកម្មនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨)

ទោះបីជា សាក្សីមានសិទ្ធិស្នើសុំអង្គជំនុំជម្រះឲ្យចេញបញ្ជាផ្តល់វិធានការការពារដល់ខ្លួនក៏ដោយ ពុំមែនរាល់ពាក្យសុំទាំងអស់សុទ្ធតែទទួលបានការយល់ព្រមនោះទេ ។ សាក្សីចាំបាច់ត្រូវតែបង្ហាញអង្គជំនុំ

ជម្រះឲ្យឃើញថា ការបង្ហាញខ្លួន និងការផ្តល់សក្ខីកម្មរបស់ខ្លួន អាចធ្វើឲ្យអាយុជីវិត សុខមាលភាព ឬក្រុមគ្រួសារ ឬញាតិជិតស្និតរបស់ខ្លួន ត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ ។[២] ក្រោយពីទទួលបាន សំណើសុំពីការពារពីសំណាក់សាក្សី ចៅក្រមនឹងសម្រេចថាតើត្រូវអនុញ្ញាត ឬពុំអនុញ្ញាត ហើយបើ អនុញ្ញាតត្រូវប្រើវិធានការបែបណា ដោយត្រូវថ្លឹងថ្លែងអំពីតម្រូវការរបស់សាក្សី និងតម្រូវការរបស់ ជនជាប់ចោទ ដើម្បីឲ្យការជំនុំជម្រះក្តីអាចធ្វើឡើងប្រកបដោយយុត្តិធម៌ និងស្មើភាព ។

អ្វីដែលគួរឲ្យកត់សម្គាល់គឺថា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលចូលជាធរមាននៅក្នុងឆ្នាំ២០០៧ ពុំបានចែងអំពីវិធានការការពារចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ការខកខាន និងការបន្សល់ទុកឲ្យមានចន្លោះខ្វះខាតនៅក្នុងក្រមនេះ បានធ្វើឲ្យសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលមានការជាប់ពាក់ព័ន្ធនឹងសំណុំរឿងក្តីនៅតុលាការក្នុងស្រុក មានការព្រួយបារម្ភ ខ្លាចរអា ឬពុំសហការក្នុងការផ្តល់ចម្លើយជូនចៅក្រមស៊ើបសួរ ឬផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដោយសារសុវត្ថិភាព សន្តិសុខ និងសុខមាលភាពរបស់អ្នកទាំងនោះពុំត្រូវបានធានាដោយច្បាប់ ។ កត្តានេះអាចនឹងធ្វើឲ្យប៉ះពាល់ដល់ដំណើរការស្វែងរកការពិត និងយុត្តិធម៌ សម្រាប់គូភាគីនៃរឿងក្តី ។ នាពេលអនាគត វិធានទាក់ទងនឹងវិធានការការពារចំពោះសាក្សី និងអ្នកដាក់ពាក្យប្តឹង គួរត្រូវដាក់បញ្ចូលបន្ថែមទៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីបង្កលក្ខណៈងាយស្រួល និងធានាសុវត្ថិភាព និងសន្តិសុខរបស់សាក្សី និងអ្នកដាក់ពាក្យបណ្តឹង ដែលអាចនឹងទទួលរងការគំរាមកំហែងដោយសារការផ្តល់សក្ខីកម្មរបស់ខ្លួន ។ម្យ៉ាងវិញទៀត ការបំពេញបន្ថែមនូវចំណុចកង្វះខាតទាំងឡាយដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ នឹងធ្វើឲ្យដំណើរការស្វែងរកយុត្តិធម៌កាន់តែមានភាពសុក្រឹត្យ ។

---

[២] វិធាន ២៩(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី៩ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ។